ទីស្ដីការក្រសួងយុត្តិធម៌

លេខ ១៥៥០ រប-៩៤

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ជម្រាបចក**

លោកប្រធានតុលាការ គ្រប់ខេត្ត ក្រុង

លោកព្រះរាជអាជ្ញាអមតុលាការគ្រប់ខេត្ត ក្រុង

**សូមជ្រាប។**

**កម្មវត្ថុ:** អំពីការផ្ដល់មតិលើរាល់របៀបចាត់ការទូទៅដែលនៅមានជួបការលំបាក ។

ខ្ញុំសូមជម្រាបលោកទាំងអស់ថា នៅចុងខែធ្នូ ឆ្នាំ១៩៩៤ ខាងមុខនេះក្រសួងយុត្តិធម៌មានគម្រោងប្រារពបើកសន្និបាតបូកសរុបការងារយុត្តិធម៌ប្រចាំឆ្នាំ១៩៩៤ ដែលនឹងត្រូវអញ្ជើញចូលរួមពីតំណាងតុលាការអយ្យការគ្រប់ខេត្ត ក្រុង ហើយនិងអង្គការនានាដែលមានការទាក់ទិន ។

ដូច្នេះសូមលោកយកចិត្តទុកដាក់លើកសំណូមពរជាមុនផ្ញើមកក្រសួងយុត្តិធម៌ អំពីគោលការណ៍ទាំងឡាយដែលត្រូវធ្វើឱ្យបានឯកភាពអំពីនីតិវិធី ទាំងការចាត់ការ ទាំងការជំនុំជម្រះ ដែលនៅខ្វះចន្លោះ ឬក៏ជួបការលំបាកក្នុងការអនុវត្ត ព្រមទាំងអំពើល្មើស ឬការវិវាទដែលកើតឡើងនាពេលថ្មីៗនេះ ដែលច្បាប់ពុំទាន់បានចែង ។

ព្រមជាមួយគ្នានេះដែរ សូមលោកធ្វើស្ថិតិអំពីរឿងមជ្ឈឹម និងឧក្រិដ្ឋ តាមប្រភេទបទល្មើស ដោយប្រៀបធៀបទៅនឹងឆ្នាំ១៩៩២ និងឆ្នាំ១៩៩៣ តើកើនឡើង ឬថយចុះប៉ុន្មានភាគរយ ។

សំណូមពរទាំងនេះត្រូវផ្ញើមកក្រសួងយុត្តិធម៌ ឱ្យបានមុនបំណាច់ខែវិច្ឆិកា ជាកំហិត ។

ធ្វើនៅភ្នំពេញ ថ្ងៃទី៤ ខែមីនា ឆ្នាំ១៩៩៤

**រដ្ឋមន្ត្រី**

**ចែម ស្ងួន**